

# ថ្ងៃទី៥ នៃយុទ្ធនាការ១៦ថ្ងៃ

# ទិវាស្ត្រីអ្នកការពារសិទ្ធិអន្តរជាតិ

# International Women Human Rights Defenders' Day

## សិទ្ធិស្ត្រី និងក្មេងស្រី៖ ការតស៊ូមតិនៅសហគមន៍

*ក្តីសង្ឃឹម និងអំណាចសម្រាប់ស្ត្រី និងក្មេងស្រីជនជាតិដើមភាគតិច ចាប់ផ្តើមពីអ្នកដឹកនាំនៅក្នុងសហគមន៍។*

ក្នុងនាមជាសមាជិកក្រុមប្រឹក្សាឃុំ លោកស្រី សារ៉ាត សារឿន ប្តេជ្ញាចិត្តដើម្បីលើកស្ទួយសហគមន៍របស់គាត់ នៅឃុំសេដា ស្រុកលំផាត់។

ជាជនជាតិទំពួននៅវ័យត្រឹមតែ ៣៥ឆ្នាំ លោកស្រី សារឿន បានចំណាយពេលប្រាំពីរឆ្នាំ ក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ ហើយលើសពីនេះទៅទៀត លោកស្រីកំពុងធ្វើការយ៉ាងសកម្ម ក្នុងការដោះស្រាយ បញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រ(GBV) ក្នុងនាមជាក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅក្នុងស្រុក។

លោកស្រី មានការប្តេជ្ញាចិត្តឥតងាករេក្នុងការជួយស្ត្រី និងក្មេងស្រីក្នុងសហគមន៍របស់គាត់។ គួបផ្សំជាមួយនឹងសកម្មភាពតស៊ូមតិក្នុងសហគមន៍ លោកស្រីទទួលបានការគោរព និងការកោតសរសើរជាទីបំផុត ។

ដំណើររបស់លោកស្រី សារឿន ឆ្ពោះទៅរកការផ្តល់សិទ្ធិអំណាច ដល់ស្ត្រីជនជាតិដើមភាគតិច នៅក្នុងសហគមន៍ ចាប់ផ្តើមជាមួយនឹងតួនាទីរបស់គាត់ក្នុងការផ្តល់ការប្រឹក្សា និងផ្តល់ជំនួយសំខាន់ៗ ទៅដល់ជនរងគ្រោះពី GBV ព្រមទាំងការគាំទ្រជំនួយផ្នែកច្បាប់។ តាមរយៈវគ្គបណ្តុះបណ្តាល និងយុទ្ធនាការផ្សព្វផ្សាយតាមភូមិ ឃុំ លោកស្រីព្យាយាមធានាអោយបានថា ស្ត្រីអាចទទួលបានការអប់រំ អំពីសិទ្ធិរបស់ពួកគេ និងត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍ពីករណី GBV។

«ពេលដែលខ្ញុំមានមោទនភាពនៅកន្លែងធ្វើការបំផុតគឺជាពេលដែលខ្ញុំបានឃើញការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងជីវិតរបស់ជនរងគ្រោះពី GBV ខណៈពេលដែលពួកគេទទួលបានភាពក្លាហានជាងមុន ក្នុងការដើរចេញពីវដ្តនៃអំពើហិង្សា។ ខ្ញុំក៏មានភាពរីករាយនៅពេលជនរងគ្រោះ GBV មានទំនុកចិត្តលើការដោះស្រាយរបស់ខ្ញុំ» លោកស្រី បាននិយាយ។

ការងាររបស់សារឿន រមែងជួបបញ្ហាប្រឈម។ ឧបសគ្គរបស់លោកស្រី រាប់តាំងពីការគាំទ្រនានាដែលនៅមានកម្រិតពីភាគីពាក់ព័ន្ធ រហូតដល់តម្រូវការបន្ទាន់ក្នុងការរកដំណោះស្រាយភ្លាមៗ ជូនជនរងគ្រោះពី GBV។ នេះជាចំណុច ដែលលោកស្រី ត្រូវផ្តល់ការណែនាំផ្លូវច្បាប់ដល់ជនរងគ្រោះ និងឆ្លងកាត់ភាពស្មុគស្មាញនៃនីតិវិធីច្បាប់។

«ដើម្បីការពារខ្លួនខ្ញុំផងដែរនៅក្នុងការងារនេះ ខ្ញុំបានសហការជាមួយអជ្ញាធរមូលដ្ឋាន ប៉ូលីសឃុំ អ្នកពាក់ព័ន្ធ និងក្រុមGBV ថ្នាក់ស្រុក ខេត្ត ដើម្បីសុំយោបល់ និងកិច្ចសហការ។ ខ្ញុំបានរក្សាទំនុកចិត្ត និងការសំងាត់ខ្ពស់បំផុត សម្រាប់ ជនរងគ្រោះ GBV។ ហើយពេលដែលខ្ញុំត្រូវចុះសួរសុខទុក្ខពួកគាត់ជាញឹកញាប់ ខ្ញុំចុះទៅតាមផ្ទះដោយមានប៉ូលីសឃុំទៅជាមួយចំពោះករណីខ្លះ» គាត់បានបន្ថែម។

ក្នុងទិវាអន្តរជាតិលុបបំបាត់អំពើហិង្សាលើស្ត្រី និងយុទ្ធនាការ១៦ថ្ងៃ សារសំខាន់របស់ លោកស្រី សារឿន ទៅកាន់សហគមន៍ បង្ហាញពីភាពបន្ទាន់ក្នុងការដោះស្រាយបញ្ហា និងទឹកចិត្តរបស់គាត់ នៅក្នុងការងារ។

> *«ខ្ញុំចង់ជំរុញឱ្យស្ត្រីជនជាតិដើមភាគតិច ត្រូវមានភាពក្លាហានក្នុងរាយការណ៍ ស្វែងរកការគាំទ្រ ដោយគ្មានការភ័យខ្លាច និងឈររួបរួមគ្នាក្នុងការប្រយុទ្ធប្រឆាំងនឹង GBV» សារឿន និយាយ។*

ការប្តេជ្ញាចិត្តរបស់សារឿន បង្កប់នូវភាពធន់ និងការផ្តល់សិទ្ធិអំណាចនៅតាមសហគមន៍ ព្រមទាំងជំរុញទឹកចិត្តស្ត្រីក្នុងសហគមន៍ជនជាតិដើមភាគតិចទំពួន។

សារឿន ចាត់ទុកយុទ្ធនាការ១៦ថ្ងៃថា ជាយុទ្ធនាការដ៏មានអត្ថន័យ ដែលផ្តោតលើការប្តេជ្ញាចិត្តក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាឱកាសដើម្បីលើកកម្ពស់ការយល់ដឹង លើកទឹកចិត្តការរាយការណ៍ និងជំរុញកិច្ចខិតខំ ប្រឹងប្រែងរួមគ្នាដើម្បីប្រយុទ្ធប្រឆាំងនឹង GBV សម្រាប់សហគមន៍ជនជាតិដើមភាគតិច។

**«ទិវានេះមានអត្ថន័យខ្លាំងណាស់ ដោយសារទិវានេះបានបង្ហាញអំពីការប្តេជ្ញាចិត្តក្នុងការទប់ស្កាត់ និងលុបបំបាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី របស់រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ។ នេះក៏ជាការរំលឹកដល់ជនរងគ្រោះ GBV និងអ្នកផ្តល់សេវាក្នុងការរាយការណ៍ និងដោះស្រាយរួមគ្នា» គាត់បានបន្ថែម។**

ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់គេហទំព័រគម្រោង ឬទាក់ទងប្រធានគ្រប់គ្រងគម្រោង លោក ផល ចាន់សត្យា chansathya.phal@care.org ឬទីប្រឹក្សាបច្ចេកទេសយេនឌ័រអង្គការឃែរកម្ពុជា លោកស្រី ហ៊ុន ស៊ីនួន sinuon.hun@care.org។